ឆ្នាំ ទី ៨ លេខ ៨៣ សប្តាហ៍ទី ២ ថ្ងៃ ទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ រាជកិច្ច ទំព័រ ៨១៨២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៨៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបង្កើតការិយាល័យអនុព័ន្ធយោធា
រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ កែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា១ : ត្រូវបានបង្កើតការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ។

មាត្រា២ : ការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជា ប្រចាំសហរដ្ឋអាមេរិក ដឹកនាំដោយអនុព័ន្ធយោធា មួយរូប និងអមដោយ ជំនួយការមួយរូប ដែលត្រូវតែងតាំងដោយ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ